BHCS

# Alameda County Behavioral Health Care Services

Behavioral Health Plan

# គំរោងការសុខភាពផ្លូវចិត្ត

កូនសៀវភៅសមាជិកសំរាប់
អ្នកទទួលមេឌីខាល់ (Medi-Cal)
ពីខោណធីអាឡាមីដា ដែលត្រូវការ
កិច្ចបំរើការនានាខាងសុខភាពផ្លូវចិត្ត

**ទូរស័ព្ទលេខ 1 (800) 491-9099**

CAMBODIAN—4th Edition

## IMPORTANT INFORMATION

If you need assistance translating this information into your home language, please call 1 (800) 491-9099.

## INFORMACIÓN IMPORTANTE

Si necesita ayuda para traducir esta información al español, por favor llame al número 1 (800) 491-9099.

## ដំណឹងសំខាន់

បើអ្នកត្រូវការជំនួយក្នុងការបកប្រែ
ដំណឹងនេះជាភាសាខ្មែរ  សូមអ្នកទូរស័ព្ទមកកាន់លេខ :

1 (800) 491-9099

## اطلاعات مهم

اکر برای ترجمه کردن این اطلاعات به فارسی
احتیاج به کمك دارید
به این شماره تلفن کنید :

1 (800) 491-9099

## 중요한 정보

이 정보에 대한
한국어 안내가 필요하시면 전화해 주십시오:

1 (800) 491-9099

## ຂ່າວສານສຳຄັນ

ຫາກທ່ານຕ້ອງການຄວາມຊ່ວຍເຫລືອ
ໃນການແປກ່າວສານນີ້ເປັນພາສາລາວ
ກະຣຸນາຕິດຕໍ່

1 (800) 491-9099

## CHỈ DẪN QUAN TRỌNG

Nếu bạn cần được giúp đỡ để
dịch tài liệu này qua tiếng **Việt**, xin bạn gọi về số:

1 (800) 491-9099

## 重要資訊

如果您需要幫助
將這些資訊翻譯成中文請洽詢：

1 (800) 491-9099

## សូមជំរាបមកដល់សមាជិក-សមាជិកា,

សូមស្វាគមន៍ពីគំរោងការសុខភាពផ្លូវចិត្ត (ហៅកាត់ BHP) ប្រចាំខោណធីអាឡាមីដា។ BHP គឺជាកម្មវិធីជួយថែទាំសុខភាពផ្លូវចិត្តប្រចាំខោណធីអាឡាមីដា។

នៅពេលណារូបអ្នកមានមេឌីខាលពីខោណធីអាឡាមីដា នោះអ្នកនឹងក្លាយទៅជាមានលក្ខខណ្ឌគ្រប់គ្រាន់សំរាប់ជំនួយថែទាំសុខភាពផ្លូវចិត្តពីកម្មវិធី BHP ប្រចាំខោណធីអាឡាមីដា។ អ្នកប្រហែលជាពុំត្រូវការជំនួយបំរើការទាំងនេះណាមួយទេមើល៍ទៅ ប៉ុន្តែបើសិនជាអ្នកត្រូវការវិញនោះ យើងខ្ញុំនៅទីនេះរង់ចាំជួយបំរើអ្នកជានិច្ច។

សូមអានកូនសៀវភៅនេះដោយយកចិត្តទុកដាក់។

យើងខ្ញុំមិនជួយបង់ថ្លៃ ឬផ្តល់កិច្ចបំរើសុខភាពនោះទេ។ យើងខ្ញុំក៏ពុំអាចជួយអ្នកពីរឿងក្រដាស់ SSI ឬក្រដាស់វែលហ្វែរដែរទេ។ ដូច្នេះសូមកុំទូរស័ព្ទមករកឲ្យយើងខ្ញុំជួយពីរឿងអស់ទាំងនេះឡើយ។

ក្នុងនាមយើងខ្ញុំជាអ្នកកាន់គំរោងការសុខភាពផ្លូវចិត្តរបស់អ្នក យើងខ្ញុំមានការទទួលខុសត្រូវយ៉ាងពិតប្រាកដ។ ក្នុងនាមរូបអ្នកជាសមាជិក-សមាជិកាម្នាក់ អ្នកក៏មានការទទួលខុសត្រូវផងដែរ។ យើងខ្ញុំមានពេទ្យវិកលចរិត, គ្រូពេទ្យខាងកែរោគក្នុងរាងកាយ និងបុគ្គលិកផ្សេងៗទៀតក្នុងកម្មវិធីរបស់យើង។ តាម



ធម្មតាយើងខ្ញុំនឹងបញ្ជូនរូបអ្នកទៅឲ្យមនុស្សណាម្នាក់ក្នុងចំណោមមនុស្សទាំងឡាយនេះជួយ។ យើងខ្ញុំអាចជួយប្រាប់អ្នកផងដែរអំពីកន្លែងផ្សេងៗទៀតដែលពុំមែនជាផ្នែកនៃ BHP របស់យើង ជាទីដែលរូបអ្នកអាចរកឲ្យគេជួយបាន។

## គោលដៅនានារបស់យើងគឺដើម្បី :

- ជួយរូបអ្នករកជំនួយបំរើការដែលអ្នកត្រូវការ។
- ធ្វើការជាមួយពេទ្យវិកលចរិត ឬគ្រូពេទ្យរបស់អ្នកខាងកែរោគក្នុងរាងកាយសំរាប់ការមើលថែទាំដែលល្អប្រសើសំរាប់អ្នក។
- ឆាប់យល់ពីសេចក្ដីត្រូវការនានារបស់អ្នក។

## យើងខ្ញុំរំពឹងចង់បានឲ្យរូបអ្នក :

- ជ្រើសរើសពេទ្យវិកលចរិត ឬគ្រូពេទ្យរបស់អ្នកខាងកែរោគក្នុងរាងកាយដែលមាននៅក្នុង BHP របស់យើង។
- ទូរស័ព្ទទៅជួបពេទ្យវិកលចរិត ឬគ្រូពេទ្យអ្នកខាងកែរោគក្នុងរាងកាយ ដើម្បីធ្វើការណាត់ជួប ហើយធ្វើតាមឱវាទដែលអ្នកបានទទួល។

## ACCESS: ទូរស័ព្ទសំរាប់ជួយសមាជិករបស់យើង

ទូរស័ព្ទសំរាប់ជួយសមាជិក-សមាជិការបស់យើងនេះឈ្មោះ អ័កសេសស៍ (ACCESS)។ ទូរស័ព្ទនេះអាចជួយឆ្លើយតបទៅនឹងសំណួរនានារបស់អ្នកអំពីការស្វែងរកជំនួយបំរើការត្រឹមត្រូវសំរាប់រូបអ្នក។ ទូរស័ព្ទនេះបើក 24 ម៉ោងក្នុងមួយថ្ងៃ ហើយបើក 7 ថ្ងៃក្នុងមួយអាទិត្យ។ សូមទូរស័ព្ទមកសាកសួរយើងខ្ញុំចុះ បើសិនជាអ្នកមានសំណួរអ្វីមួយ។ ទូរស័ព្ទមានលេខដូចតទៅនេះ 1 (800) 491-9099 ឬ (510) 346-1000។

បុគ្គលិកធ្វើការនៅទីអ័កសេសស៍នេះ ចេះនិយាយភាសានានាក្រៅពីភាសាអង់គ្លេស។ យើងខ្ញុំក៏មានអ្នកជួយបកប្រែភាសាជូនអ្នកផងដែរ បើសិនជាអ្នកពុំចេះនិយាយភាសាអង់គ្លេសទេនោះ។ យើងខ្ញុំក៏អាចជួយអ្នកបានផងដែរ បើសិនអ្នកមានការពិបាកមើលពុំសូវឃើញ ឬស្តាប់ពុំសូវឮ។

## ទូរស័ព្ទអ័កសេសស៍នេះនឹងជួយរូបអ្នកក្នុងការ :

- រកចម្លើយទៅនឹងសំណួរនានារបស់អ្នកអំពីជំនួយព្យាបាលសុខភាពផ្លូវចិត្ត និងសុរា ហើយនិងគ្រឿងញៀន។
- ស្វែងរកថាតើគេមានជំនួយបំរើការអ្វីខ្លះ។
- គិតមើលថាតើជំនួយបំរើការអ្វីខ្លះទៅដែលរូបអ្នកត្រូវការ។
- ជ្រើសរើសពេទ្យវិកលចរិត ឬគ្រូពេទ្យខាងកែរោគក្នុងរាងកាយ ដែលនៅជិតទីលំនៅដ្ឋានរបស់អ្នក។



- ទទួលការព្យាបាលសុខភាពផ្លូវចិត្ត ឬការប្រើសារធាតុច្រើនពេកសំរាប់កូនៗរបស់អ្នក។
- ទទួលដំណឹងអំពីជំនួយបំរើការនានាសំរាប់សេចក្តីត្រូវការពិសេស។
- ជួយគិតមើលពីបញ្ហាណាដែលអ្នកអាចមាន ក្នុងការរកជំនួយបំរើការពីយើងខ្ញុំ។

## តើជំនួយបំរើមុខការអ្វីខ្លះដែលអ្នកអាចទទួលបាន?

គំរោងការសុខភាពផ្លូវចិត្តប្រចាំខោណធីអាឡាមីដានេះជួយអ្នកក្នុងការទទួល និងការបង់ថ្លៃលើជំនួយបំរើការនានាដូចតទៅ :

- ការនាំចូលក្នុងកម្មវិធី : នេះនៅពេលណាដែលអ្នកមកដល់ទីកន្លែងជួយបំរើការជាលើកដំបូង ហើយបានផ្តល់ពត៌មានពិតអំពីខ្លួនអ្នកទៅឲ្យបុគ្គលិក។
- ការពិនិត្យសុខភាព : បុគ្គលិកនឹងសាកសួរយកពត៌មានថែមទៀតពីរូបអ្នកដើម្បីឲ្យយល់ពីសេចក្តីត្រូវការរបស់អ្នក, អំពីមធ្យោបាយដ៏ប្រសើរដើម្បីបំពេញសេចក្តីត្រូវការរបស់អ្នក, ហើយនិងទីកន្លែងដែលល្អប្រសើរក្នុងកិច្ចបំរើការនានា។
- ការថែទាំសុខភាពក្នុងមន្ទីរពេទ្យ : បុគ្គលិកអាចស្នើសុំឲ្យអ្នកស្នាក់នៅក្នុងមន្ទីរពេទ្យដែលក្នុងនោះនឹងមានការជួយថែទាំសុខភាពអ្នកជូនបាន 24 ម៉ោងក្នុងមួយថ្ងៃ។
- ការព្យាបាលអ្នកជម្ងឺក្រៅមន្ទីរពេទ្យ : លោកអ្នកអាចជួបពេទ្យវិកលចរិត ឬគ្រូពេទ្យខាងកែរោគក្នុងរាងកាយម្នាក់នៅក្នុងការិយាល័យរបស់ពួកគេដើម្បីជួយពិនិត្យមើលជម្ងឺអ្នក។

- ការជួយសង្គ្រោះជាបន្ទាន់ ឬវិបត្តិវិកលចរិត ៖ អ្នកអាចប្រើជំនួយបំរើការនេះបាន 24 ម៉ោងក្នុងមួយថ្ងៃ នៅពេលអ្នកត្រូវការជួយ ហើយពុំអាចរង់ចាំពេលណាត់ជួបជាមួយនឹងពេទ្យវិកលចរិត, គ្រូពេទ្យខាងកែរោគក្នុងរាងកាយ, ឬកិច្ចបំរើសុខភាពផ្លូវចិត្តផ្សេងៗទៀត។
- ថ្នាំពេទ្យ ៖ បុគ្គលិកអាចស្នើសុំឲ្យរូបអ្នកទៅជួបវេជ្ជបណ្ឌិតដែលជាអ្នកអាចផ្ដល់ឱវាទអំពីថ្នាំពេទ្យដែលនឹងជួយរូបអ្នកសំរាប់មួយរយៈពេល។
- កុមារ និងយុវសិស្ស ៖ កុមារទាំងឡាយអាចជួបពេទ្យវិកលចរិត ឬគ្រូពេទ្យម្នាក់ខាងកែរោគក្នុងរាងកាយដែលយល់ដឹងពីរបៀបធ្វើការបានយ៉ាងល្អប្រសើរជាមួយកុមារ។ ហើយនិងក្រុមគ្រួសាររបស់ពួកគេ។

## ការជួយសង្គ្រោះជាបន្ទាន់

BHP នេះជួយបង់ថ្លៃលើជំនួយជួយសង្គ្រោះជាបន្ទាន់ក្នុងគ្រាមានវិកលចរិត។ បើសិនជាអ្នកត្រូវការជួយសង្គ្រោះជាបន្ទាន់នោះអ្នកត្រូវតែចាត់ការឲ្យបានឆាប់រហ័ស។ សូមចុចលេខ 911 ឬចេញទៅមន្ទីរពេទ្យដែលនៅជិតអ្នកបំផុត។ បើសិនជាអ្នកពុំដឹងថាវាជារឿងត្រូវការជួយសង្គ្រោះជាបន្ទាន់នោះទេ សូមអ្នកទូរស័ព្ទទៅកាន់ទីអ៊ំកសេសស៍នៅលេខ 1 (800) 491-9099។

បើសិនជាអ្នកត្រូវការការព្យាបាលសុខភាពផ្លូវចិត្ត និងបញ្ហាញៀនស្រា និងគ្រឿងញៀនផ្សេងទៀត បន្ទាប់ពីអ្នកបានទទួល

ការជួយមើលថែទាំសុខភាពជាបន្ទាន់នោះមក សូមទូរស័ព្ទមកជួបនឹងយើងខ្ញុំនៅលេខ 1 (800) 491-9099។ យើងខ្ញុំនឹងជួយអ្នកធ្វើការណាត់ជួប។

## ជំនួយបំរើការនៅក្រៅខោណធី

អ៉ក់សេសស័នឹងជួយអ្នកក្នុងការទទួលជំនួយបំរើការដែលពុំមែនជារឿងត្រូវជួយសង្គ្រោះជាបន្ទាន់នៅពេលណាអ្នកមិននៅក្នុងខោណធីអាឡាមីដា ។ បើសិនជាអ្នកត្រូវការជួយសង្គ្រោះជាបន្ទាន់ក្នុងខណៈដែលអ្នកនៅទីឆ្ងាយពីខោណធីអាឡាមីដា នោះ BHP នឹងបង់ថ្លៃជូនលើជំនួយជួយសង្គ្រោះជាបន្ទាន់របស់អ្នកផ្នែកវិកលចរិត។

កម្មវិធី BHP នឹងមិនធានាជួយបង់ថ្លៃទៅលើការជួយផ្នែកបញ្ហាញៀនស្រា និងគ្រឿងញៀននៅក្រៅខោណធីអាឡាមីដាឡើយ។ ខោណធីដែលអ្នកកំពុងឋិតនៅនោះ ប្រហែលជាអាចជួយបង់ថ្លៃសំរាប់ជំនួយបំរើការនានាលើបញ្ហាទាំងនេះ។

សូមនិយាយប្រាប់អ៉ក់សេសស័ឲ្យបានដឹងអំពីជំនួយបំរើការនានានៅក្រៅខោណធីដែលអ្នកបានទទួលនោះឲ្យបានឆាប់រហ័សបំផុត។

## ថ្នាំពេទ្យ

មេឌីខាល (Medi-Cal) អាចចេញថ្លៃថ្នាំពេទ្យនានាដែលពេទ្យវិកលចរិតនៃអ្នកបានណែនាំរូបអ្នក។ អ្នកត្រូវការវេជ្ជបញ្ជាជាលាយលក្ខណ៍អក្សរមួយច្បាប់ចេញពីពេទ្យវិកលចរិតរបស់អ្នកសំរាប់ថ្នាំទាំងនេះ។

## សិទ្ធិរក្សារឿងសម្ងាត់ផ្ទាល់ខ្លួន

កម្មវិធី BHP នេះជួយការពាររឿងផ្ទាល់ខ្លួនរបស់អ្នក ។ យើងខ្ញុំនឹងមិនផ្តល់ពត៌មានអំពីរូបអ្នក ឬអំពីការព្យាបាលរបស់អ្នកទៅឲ្យអ្នកក្រៅដឹងឡើយ លុះត្រាតែអ្នកផ្តល់ការអនុញ្ញាតឲ្យយើងខ្ញុំ ឬលុះត្រាតែច្បាប់អនុញ្ញាតឲ្យធ្វើ ។ ជាឧទាហរណ៍ : យើងខ្ញុំអាចត្រូវការបញ្ចេញពត៌មាន បើសិនវាជារឿងសំខាន់សំរាប់ថែទាំក្នុងគ្រាជួយសង្គ្រោះជាបន្ទាន់។

## សិទ្ធិនានារបស់សមាជិក-សមាជិកា

អ្នកមានសិទ្ធិ :

- ទទួលជំនួយបំរើការនៅពេលខ្លះ និងនៅតាមកន្លែងនានាដែលល្អគួរសមសំរាប់រូបអ្នក។
- សុំជំនួយបំរើការនានានៅតាមទីដែលមានបុគ្គលិកយល់ដឹងអំពីវប្បធម៌របស់អ្នក ហើយចេះនិយាយភាសារបស់អ្នក។
- ទទួលជំនួយជួយបំរើការពីបុគ្គលិកដែលមានសមត្ថភាពយល់ពីវប្បធម៌របស់អ្នក។

- ទទួលបាននូវការប្រព្រឹត្តចំពោះរូបអ្នកប្រកបដោយភាពគួរសម ដោយភាពថ្លៃថ្នូរ ហើយនិងដោយក្តីគោរព។
- ដឹងទាំងអស់អំពីជម្ងឺដែលរូបអ្នកមាន។
- ចូលរួមក្នុងកិច្ចសំរេចចិត្តលើការព្យាបាលរបស់អ្នក។
- សួរសំណួរអំពីជម្ងឺ ឬការថែទាំសុខភាពរបស់អ្នក មុននឹងការព្យាបាលមួយត្រូវបានចាប់ផ្តើមឡើង ហើយនិងក្នុងខណៈដែលអ្នកកំពុងត្រូវបានឋិតនៅក្នុងការព្យាបាល។
- បដិសេធបោលនូវការព្យាបាលណាដែលពុំមានលក្ខណៈជួយសង្គ្រោះជាបន្ទាន់ ហើយមានសិទ្ធដឹងថាតើវាអាចកើតឡើងយ៉ាងណាខ្លះ បើសិនជាអ្នកពុំព្រមឲ្យគេព្យាបាល។
- តម្រូវឲ្យសំណុំរឿងរបស់អ្នក ព្រមទាំងអ្វីៗទាំងអស់ដែលអ្នកបាននិយាយប្រាប់ដល់វេជ្ជបណ្ឌិត ឬគ្រូពេទ្យអ្នកខាងកែរោគក្នុងរាងកាយ/អ្នកផ្តល់ឱវាទនោះ ត្រូវរក្សាទុកជាក់ជារឿងសម្ងាត់ផ្ទាល់ខ្លួន។ ពត៌មាននឹងមិនត្រូវលាតត្រដាងជាសាធារណៈដោយគ្មានការអនុញ្ញាតពីរូបអ្នកឡើយ លុះត្រាតែច្បាប់អនុញ្ញាតយ៉ាងច្បាស់លាស់។
- ជ្រើសរើសពេទ្យវិកលចរិត ឬគ្រូពេទ្យខាងកែរោគក្នុងរាងកាយ ដែលអ្នកចូលចិត្តជាគេនៅក្នុងកម្មវិធីរបស់យើងខ្ញុំ។
- បញ្ចេញយោបល់អំពីការពុំពេញចិត្តរបស់អ្នកទៅជូនដល់កម្មវិធី BHP ពីរឿងកិច្ចបំរើការនានា និងទទួលចម្លើយឲ្យបានសមទៅតាមពេលវេលាហុចឲ្យ។
- ស្នើរើសំណុំរឿងរបស់អ្នកឡើងវិញ ឬទទួលសេចក្តីសង្ខេបខ្លីៗ។

- ស្នើសុំឲ្យគេធ្វើការកែប្រែលើសំណុំរឿងរបស់អ្នក។
- ស្នើសុំយោបល់ពីគ្រូពេទ្យផ្សេងម្នាក់ទៀតអំពីការថែទាំដែលអ្នកបានទទួល ឬបានផ្តល់ជូនជាអនុសាសន៍។
- ទទួលដំណឹងជូនជ្រាប់អំពីវិន័យ និងការផ្លាស់ប្តូរណាមួយរបស់កម្មវិធី BHP ដែលបានសំរេចហើយ។
- រួចពីការចាប់ខ្ទប់មិនឲ្យរើ ឬរួចពីការដាក់ឲ្យនៅដាច់ឆ្ងាយពីគេក្នុងគ្រប់រូបភាពដែលត្រូវបានប្រើប្រាសឡើងដើម្បីបង្ខិតបង្ខំ, ដាក់វិន័យ, ងាយស្រួល ឬដើម្បីសងសឹក។
- ទទួលពត៌មានអំពីសិទ្ធិ និងផលប្រយោជន៍នានារបស់អ្នកដែលរូបអ្នកគួរបានទទួល។
- ទទួលពត៌មានអំពីប្រភេទ និងកំរិតនៃកិច្ចបំរើការនានាដែលអ្នកគួរទទួល។
- ទទួលជំនួយបំរើការនានាដែលមានជូន និងអាចរកបាន។

## ការទទួលខុសត្រូវរបស់សមាជិក-សមាជិក

អ្នកមានការទទួលខុសត្រូវលើការ :

- ចេះគោរព និងប្រព្រឹត្តចំពោះអ្នកដទៃៗទៀតប្រកបដោយមានភាពថ្លៃថ្នូរ។
- និយាយប្រាប់វេជ្ជបណ្ឌិត ឬគ្រូពេទ្យរបស់អ្នកខាងកែរោគក្នុងរាងកាយ/អ្នកផ្តល់ឱវាទ អំពីបញ្ហានានារបស់អ្នក ព្រមទាំងចេះសាកសួរជាសំណួរផងដែរ។

- ធ្វើការណាត់ជួបហើយរក្សាវាទុកកុំឲ្យភ្លេច ត្រូវទៅជួបពេទ្យឲ្យបានទាន់ពេលវេលា ហើយបើសិនជាអ្នកមិនអាចទៅជួបពេទ្យបានទៅតាមការណាត់ទេ នោះអ្នកត្រូវទូរស័ព្ទទៅឲ្យគេបានជ្រាបពីរឿងហ្នឹងផង។
- ប្រាប់វេជ្ជបណ្ឌិត ឬគ្រូពេទ្យរបស់អ្នកខាងកែរោគក្នុងរាងកាយឲ្យបានដឹងបើសិនជាអ្នកមិនយល់ស្របទៅនឹងការព្យាបាល ឬបើសិនជាអ្នកចង់ឲ្យគេឈប់ធ្វើការព្យាបាលតទៅទៀត។
- សិក្សា និងធ្វើតាមច្បាប់ទម្លាប់នៃកម្មវិធី BHP។

## បើសិនជាអ្នកមានសារទុក្ខ

កម្មវិធី BHP ចង់ឲ្យអ្នកទទួលបាននូវការជួយថែទាំយ៉ាងល្អប្រសើរបំផុត។ បើសិនជាមានការអ្វីកើតឡើងខុសទំនង នោះយើងខ្ញុំចង់ដឹងពីរឿងហ្នឹង។ សូមនិយាយប្រាប់ពេទ្យវិកលចរិត ឬគ្រូពេទ្យរបស់អ្នកខាងកែរោគក្នុងរាងកាយ, អ្នកត្រួតពិនិត្យកម្មវិធី, ឬនាយក-នាយិកានៃកម្មវិធីណាមួយរបស់អ្នកក៏បាន។ អ្នកអាចទូរស័ព្ទមកកាន់ការិយាល័យជំនួយការនៃអ្នកប្រើប្រាស់នៅលេខ 1 (800) 779-0787 ដែលជាទីអ្នកអាចទទួលបាននូវជំនួយដោះស្រាយបញ្ហាបារម្ភនានា។

មិត្តភ័ក្ត សមាជិកនៃគ្រួសារ ឬពេទ្យវិកលចរិតអាចជួយនិយាយប្រាប់អំពីបញ្ហាបារម្ភនានារបស់អ្នកដែលរូបអ្នកមានជូនអ្នកបាន។ បើសិសត្រូវការចាំបាច់ នោះ BHP នឹងរកអ្នកជួយបកប្រែភាសាជូន បើសិនជាអ្នកមិនចេះនិយាយអង់គ្លេសទេនោះ។



## ដំណើរការថ្លែងសារទុក្ខ

កម្មវិធី BHP នឹងធ្វើការជួយពីរឿងថ្លែងសារទុក្ខជូនឲ្យបានឆាប់រហ័ស។ អ្នកមានសិទ្ធិតាមផ្លូវការដាក់ប្តឹងជាលាយលក្ខណ៍អក្សរអំពីសារទុក្ខ។ គណៈកម្មាធិការនៃកម្មវិធី BHP ខាងសារទុក្ខ/បណ្តឹងតវ៉ា នឹងធ្វើការពិនិត្យសើរើឡើងវិញលើសារទុក្ខរបស់អ្នក។ ការិយាល័យផ្នែកជួយអ្នកប្រើប្រាស់របស់យើងខ្ញុំតាមរយៈទូរស័ព្ទលេខ 1 (800) 779-0787 នេះនឹងជួយអ្នកក្នុងការរៀបចំពាក្យថ្លែងសារទុក្ខរបស់អ្នកយកទៅដាក់ជូនដល់គណៈកម្មាធិការ។ អ្នកអាចរកមនុស្សម្នាក់ទៀតបានក្នុងការមកជួយរត់ការ ឬជួយនាំពាំពាក្យឲ្យអ្នកនៅពេលណាមួយក៏បាន។ គ្មានជនគ្មានជនណាម្នាក់អាចប្រព្រឹត្តទៅលើរូបអ្នកខុសទំនងដោយសារតែអ្នកបានរាយការណ៍ប្រាប់ពីការថ្លែងសារទុក្ខរបស់ឡើយ។

## ជំនុំជំរះក្តីនៃរដ្ឋប្រកបដោយយុត្តិធម៌

អ្នកមានសិទ្ធិទទួលការជំនុំជំរះក្តីដោយយុត្តិធម៌ពីរដ្ឋនៅពេលណាកម្មវិធី BHP ប្រាប់អ្នកថារូបអ្នកពុំអាចទទួលជំនួយដែលអ្នកបានដាក់សំណើរសុំ ឬជំនួយដែលអ្នកធ្លាប់បានទទួលនោះ ឬថាជំនួយដែលអ្នកកំពុងតែទទួលនេះនឹងត្រូវបានកាត់បន្ថយចុះតិចជាងមុន ឬត្រូវអស់ត្រឹមនេះ។ អ្នកអាចផងដែរស្នើសុំបើកសវនាការប្រកបដោយយុត្តិធម៌មួយ បើសិនជាកម្មវិធី BHP ខកខានផ្តល់ជំនួយបំរើការនានាឲ្យបានទាន់ពេលវេលា ឬខកខានប្រព្រឹតក្នុងគំរោងពេលវេលាដែលបានអនុញ្ញាត ទាក់ទិនទៅនឹងការថ្លែងសារទុក្ខ ឬការស្នើសុំរបស់អ្នក។ កម្មវិធី BHP

នឹងផ្តល់ជូនអ្នកនូវដំណឹងអំពីចំណាត់ការនៅពេលណាចំណាត់ការនានាទាំងនេះកើតឡើង។ អ្នកមានសិទ្ធិស្នើសុំការសំរេចណាមួយជាថ្មីនៅពេលណាមួយក៏បាន នៅមុនថ្ងៃ នៅក្នុងអំឡុងពេល ឬនៅក្នុងរយៈពេល 90 ថ្ងៃ បន្ទាប់ពីរូបអ្នកបានបញ្ចប់ដំណើរការថ្លែងពីសារទុក្ខ។

ដើម្បីស្នើសុំការជំនុំជំរះរឿងក្តីបាននោះ អ្នកត្រូវបំពេញក្រដាស់ស្នើសុំបើកការជំនុំជំរះរឿងក្តីដោយយុត្តិធម៌ពីរដ្ឋ ឬក៏ទូរស័ព្ទមកកាន់ក្រុមប្រតិកម្មតប និងក្រុមសាកសួរពត៌មាន តាមរយៈទូរស័ព្ទលេខ 1 (800) 743-8525។

កម្មវិធី BHP នឹងបន្តបង់ថ្លៃលើជំនួយនានាដែលអ្នកធ្លាប់បានទទួលនោះ បើសិនជាក្រដាស់បំពេញរបស់អ្នកត្រូវបានដាក់ទាន់ក្នុងរយៈពេល 10 ថ្ងៃ ចាប់ពីថ្ងៃដែលអ្នកបានផ្ញើតាមប៉ុស្តិ៍សំបុត្រ ឬបានយកដំណឹងពីចំណាត់ការនេះទៅជូនផ្ទាល់ដៃ ។ យើងមានពត៌មានជាលាយលក្ខណ៍អក្សរថែមទៀតអំពីក្រដាស់ជូនដំណឹងអំពីចំណាត់ការនេះ។

## ទទួលយោបល់ពីគ្រូពេទ្យផ្សេងម្នាក់ទៀត ឬសុំប្តូរផ្លាស់ពេទ្យវិកលចរិតរបស់អ្នក

បើសិនជាអ្នកត្រូវការពេទ្យវិកលចរិតផ្សេងម្នាក់ទៀតឲ្យជួយផ្តល់យោបល់ពីបញ្ហាសុខភាពរបស់អ្នក, ពីជំនួយបំរើការនានាដែលអ្នកត្រូវការ, ឬក៏អ្នកមានបំណងចង់ប្តូរផ្លាស់ពេទ្យវិកលចរិត ឬគ្រូពេទ្យរបស់អ្នកខាងកែរោគក្នុងរាងកាយនោះ សូមទូរស័ព្ទមកកាន់ទីអ៊ីកសេស នៅលេខ 1 (800) 491-9099។

## សំរាប់ព័ត៌មានលំអិតថែមទៀត

បើសិនជាអ្នកចង់បានការរៀបរាប់លំអិតថែមទៀត
អំពីព័ត៌មានដូចមាននៅក្នុងកូនសៀវភៅនេះ, សូមទាក់ទង
អ័កសេសស័នៅលេខ 1 (800) 491-9099 ។

**Alameda County**
**Behavioral Health Care Services**

គំរោងការសំរាប់សុខភាពផ្លូវចិត្ត

A Department of
Alameda County Health Care Services Agency